**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ២១៤.អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការកែសម្រួលមាត្រា៥ មាត្រា១១ មាត្រា១២ មាត្រា១៣ មាត្រា១៨ មាត្រា២២ មាត្រា២៣ និង មាត្រា២៨ នៃអនុក្រឹត្យលេខ ១៤៥ អនក្រ.បក ចុះថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១២ ស្តីពីការបង្កើតប្រព័ន្ធស្បៀងបម្រុងកម្ពុជា

**រាជរដ្ឋាភិបាលកម្ពុជា**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំង
- រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម

- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៦៩៦/០៣ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៥ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងពូជដំណាំនិងសិទ្ធិអ្នកបង្កាត់ពូជដំណាំ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧១៥/០០៧ ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងគ្រោះមហន្តរាយ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៤៤៤ ចុះថ្ងៃទី៣១ ខែធ្នូឆ្នាំ២០១៣ ស្តីពីការបង្កើតគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៥/១១៤១ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៥ ស្តីពីការប្រព្រឹត្តទៅរបស់គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៩/៨៦៦ ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០០៩ ស្តីពីការបង្កើតក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ
- បានឃើញអនុក្រឹត្យលេខ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ១១៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១៦ ស្តីពីការដំឡើងនាយកដ្ឋានដោះស្រាយផលប៉ះពាល់ដោយសារគម្រោងអភិវឌ្ឍន៍ ទៅជាអគ្គនាយកដ្ឋានដោះស្រាយផលប៉ះពាល់ដោយសារគម្រោងអភិវឌ្ឍន៍ ដំឡើងនាយកដ្ឋានសហប្រតិបត្តិការនិងគ្រប់គ្រងបំណុល ទៅជាអគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិនិងគ្រប់គ្រងបំណុល និងបង្កើតនាយកដ្ឋានសវនកម្មបច្ចេកវិទ្យាព័ត៌មាន ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ៧២ អនក្រ.បក ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការបង្កើតក្រុមហ៊ុនហ្រ្វីនគ្រេជ
- បានឃើញអនុក្រឹត្យលេខ១១៨ អនក្រ.បក ចុះថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០០២ ស្តីពីការកែប្រែមាត្រា៧ នៃអនុក្រឹត្យលេខ៧២ អនក្រ.បក ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការបង្កើតក្រុមហ៊ុនហ្រ្វីនគ្រេជ
- បានឃើញអនុក្រឹត្យលេខ១៨៨ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៨ ស្តីពីការកែសម្រួលអគ្គនាយកដ្ឋាននៃក្រសួងទៅជាអគ្គលេខាធិការដ្ឋាន ការដំឡើងរដ្ឋបាលព្រៃឈើ រដ្ឋបាលជលផលឱ្យមានថ្នាក់ស្មើអគ្គនាយកដ្ឋាន ការដំឡើងនាយកដ្ឋានក្សេត្រសាស្ត្រនិងកែលម្អដីកសិកម្មឱ្យទៅជាអគ្គនាយកដ្ឋានកសិកម្ម និងការកែសម្រួលអគ្គនាយកដ្ឋានចំការកៅស៊ូ ទៅជាអគ្គនាយកដ្ឋានកៅស៊ូស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- បានឃើញអនុក្រឹត្យលេខ១៤៥ អនក្រ.បក ចុះថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១២ ស្តីពីការបង្កើតប្រព័ន្ធស្បៀងបម្រុងកម្ពុជា
- យោងតាមសំណើរបស់ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សម្រេច

**មាត្រាមួយ.-**

មាត្រា៥ មាត្រា១១ មាត្រា១២ មាត្រា១៣ មាត្រា១៨ មាត្រា២២ មាត្រា២៣ និងមាត្រា២៨ នៃអនុក្រឹត្យលេខ ១៤៥ អនក្រ.បកចុះ ថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១២ ស្តីពីការបង្កើតប្រព័ន្ធស្បៀងបម្រុងកម្ពុជាត្រូវបានធ្វើការកែសម្រួល ដូចតទៅ÷

**មាត្រា៥ ថ្មី.-**

**ប.ស.ប.ក.** ស្ថិតក្រោមការដឹកនាំនិងបញ្ជាផ្ទាល់របស់នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា។

គណៈកម្មាធិការ **ប.ស.ប.ក.** ត្រូវបានបង្កើតឡើងដើម្បីបំពេញមុខងារជាសេនាធិការផ្ទាល់របស់នាយករដ្ឋមន្ត្រីក្នុងការគ្រប់គ្រងដំណើរការនិងការរៀបចំសេចក្តីព្រាងគោលនយោបាយនានាសម្រាប់ **ប.ស.ប.ក.**។

គណៈកម្មាធិការ **ប.ស.ប.ក.** មានសមាសភាពដូចខាងក្រោម÷

| | |
|---|---|
| - តំណាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | ប្រធាន |
| - តំណាងគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ | អនុប្រធាន |
| - តំណាងទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| - តំណាងក្រសួងមហាផ្ទៃ | សមាជិក |
| - តំណាងក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ | សមាជិក |
| - តំណាងក្រសួងពាណិជ្ជកម្ម | សមាជិក |
| - តំណាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| - តំណាងកាកបាទក្រហមកម្ពុជា | សមាជិក។ |

សមាសភាពជាក់ស្តែងនៃ គណៈកម្មាធិការ **ប.ស.ប.ក.** ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល។

គណៈកម្មាធិការ **ប.ស.ប.ក.** មានលេខាធិការដ្ឋានមួយដែលស្ថិតក្នុងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ជាសេនាធិការក្នុងការបំពេញមុខងារនិងភារកិច្ចរបស់ខ្លួន។

លេខាធិការដ្ឋានគណៈកម្មាធិការ **ប.ស.ប.ក.** មានប្រភពធនធានផ្គត់ផ្គង់ដោយថវិកាជាតិ ជាកញ្ចប់ថវិកាដោយឡែក នៅក្នុងក្របខ័ណ្ឌថវិកាប្រចាំឆ្នាំរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងមានសិទ្ធិទទួល និង គ្រប់គ្រងមូលនិធិ ដែលបានមកពីប្រភពហិរញ្ញប្បទានសហប្រតិបត្តិការបរទេស និងពីប្រភពផ្សេងទៀត សម្រាប់ចំណាយលើការសិក្សាស្រាវជ្រាវ សេវារដ្ឋបាល និងសម្រាប់បម្រើសេចក្តីត្រូវការ ក្នុងការផ្គត់ផ្គង់សម្ភារៈ បរិក្ខារ និងការឧបត្ថម្ភផ្សេងៗតាមការចាំបាច់ក្នុងគោលដៅធានាប្រសិទ្ធភាពក្នុងការបំពេញមុខងារ និងភារកិច្ចរបស់ខ្លួន។

ការរៀបចំនិងការប្រព្រឹត្តទៅរបស់លេខាធិការដ្ឋានគណៈកម្មាធិការ **ប.ស.ប.ក.** ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា១១ ថ្មី.-**

សន្និធិស្បៀងបម្រុងដំបូងជាអង្ករចំនួន ១០ ០០០ (ដប់ពាន់) តោន ត្រូវគ្រប់គ្រងដោយក្រុមហ៊ុនគ្រឹនគ្រេដ ដែលជាសេនាធិការឱ្យក្រសួងពាណិជ្ជកម្មដោយសហការជាមួយក្រុមហ៊ុនឯកជន តាមរយៈកិច្ចសន្យាសហការជាដៃគូ។ ក្រុមហ៊ុនគ្រឹនគ្រេដ ត្រូវបានអនុញ្ញាតឱ្យរក្សាទុកសន្និធិស្បៀងបម្រុងជាស្រូវ តាមបរិមាណសមមូលនឹងអង្ករដែលបានកំណត់។

សន្និធិស្បៀងបម្រុងដំបូងជាអង្ករ ត្រូវរក្សាទុកយ៉ាងហ្មត់ចត់ ដោយអនុលោមតាមលក្ខខណ្ឌបច្ចេកទេសនៃការរក្សាទុក។

សន្និធិស្បៀងបម្រុងដំបូងជាសាច់ប្រាក់សមមូលនឹងអង្ករចំនួន ៦ ០០០ (ប្រាំមួយពាន់) តោន ត្រូវគ្រប់គ្រងដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា១២ ថ្មី.-**

**ប.ស.ប.គ.** ត្រូវមានសន្និធិគ្រាប់ពូជបម្រុងដំបូង តាមការកំណត់ ដូចខាងក្រោម÷

- សន្និធិគ្រាប់ពូជស្រូវសរុបសមមូលចំនួន ៣ ០០០ (បីពាន់) តោន ដែលក្នុងនោះ ២ ០០០ (ពីរពាន់) តោន ជាគ្រាប់ពូជ និង ១ ០០០ (មួយពាន់) តោនផ្សេងទៀតជាសាច់ប្រាក់។
- សន្និធិគ្រាប់ពូជបន្លែនិងគ្រាប់ពូជដំណាំរួមផ្សំផ្សេងៗទៀតសរុបសមមូលចំនួន ៥០ (ហាសិប) តោន ដែលក្នុងនោះ ២៥ (ម្ភៃប្រាំ) តោន ជាគ្រាប់ពូជ និង ២៥ (ម្ភៃប្រាំ) តោនផ្សេងទៀតជាសាច់ប្រាក់។

ក្នុងករណីចាំបាច់ សន្និធិគ្រាប់ពូជបម្រុងដំបូងដែលបានកំណត់ខាងលើ អាចកែសម្រួលដោយនាយករដ្ឋមន្ត្រី តាមសំណើរបស់គណៈកម្មាធិការ **ប.ស.ប.គ.**។

**មាត្រា១៣ ថ្មី.-**

សន្និធិគ្រាប់ពូជស្រូវបម្រុងដំបូងចំនួន ២ ០០០ (ពីរពាន់) តោន និងសន្និធិគ្រាប់ពូជបន្លែនិងគ្រាប់ពូជដំណាំរួមផ្សំផ្សេងៗដំបូងចំនួន ២៥ (ម្ភៃប្រាំ) តោន ត្រូវគ្រប់គ្រងដោយអគ្គនាយកដ្ឋានកសិកម្មដែលជាសេនាធិការឱ្យក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដោយផ្ទាល់ ឬតាមរយៈក្រុមហ៊ុនផលិតគ្រាប់ពូជនិងសហគមន៍កសិករដែលផលិតគ្រាប់ពូជស្រូវ គ្រាប់ពូជបន្លែ និងគ្រាប់ពូជដំណាំរួមផ្សំផ្សេងៗ។

សន្និធិគ្រាប់ពូជស្រូវបម្រុងដំបូងជាសាច់ប្រាក់សមមូលនឹងគ្រាប់ពូជចំនួន ១ ០០០ (មួយពាន់) តោន និងសន្និធិគ្រាប់ពូជបន្លែនិងគ្រាប់ពូជដំណាំរួមផ្សំផ្សេងៗបម្រុងដំបូងជាសាច់ប្រាក់សមមូលនឹងគ្រាប់ពូជចំនួន ២៥ (ម្ភៃប្រាំ) តោន ត្រូវគ្រប់គ្រងដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

គ្រាប់ពូជស្រូវ គ្រាប់ពូជបន្លែ និងគ្រាប់ពូជដំណាំរួមផ្សំផ្សេងៗទៀត ដែលរក្សាទុកជាសន្និធិគ្រាប់ពូជបម្រុងរបស់ **ប.ស.ប.គ.** ត្រូវផលិតនិងរក្សាទុកយ៉ាងហ្មត់ចត់ ដោយអនុលោមតាមលក្ខខណ្ឌបច្ចេកទេសនៃការផលិតនិងការរក្សាទុកគ្រាប់ពូជ។

**មាត្រា១៨ ថ្មី.-**

ក្នុងករណីមានតម្រូវការសង្គ្រោះបន្ទាន់ដោយសារគ្រោះមហន្តរាយ ឬគ្រោះអាសន្ននានា គ្រាប់ពូជបម្រុងមានគុណភាពត្រូវចែកចាយដោយឥតគិតថ្លៃជូនដល់ប្រជាកសិកររងគ្រោះដែលក្រីក្រ និងងាយរងគ្រោះ។

**មាត្រា២២ ថ្មី.-**

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ប្រគល់តួនាទីជាអង្គភាពអនុវត្តក្នុង **ប.ស.ប.គ** ដល់លេខាធិការដ្ឋាននៃគណៈកម្មាធិការ **ប.ស.ប.គ.** ដោយមានភារកិច្ចបន្ថែម ដូចខាងក្រោម÷

- គ្រប់គ្រងគណនីតម្កល់មូលនិធិប្រាក់បម្រុងសម្រាប់កិច្ចលទ្ធកម្មការថែរក្សាការគ្រប់គ្រង ការដឹកជញ្ជូន និងប្រតិបត្តិការផ្សេងៗពាក់ព័ន្ធនឹងស្បៀងនិងគ្រាប់ពូជបម្រុងសម្រាប់ **ប.ស.ប.គ.**
- តាមដាននិងត្រួតពិនិត្យការប្រើប្រាស់មូលនិធិប្រាក់បម្រុងក្នុងការទិញស្បៀង និងគ្រាប់ពូជបម្រុងសម្រាប់ **ប.ស.ប.គ.**
- រៀបចំបម្រុងទុកថវិកាសម្រាប់គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ក្រសួងពាណិជ្ជកម្ម និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្នុងការថែរក្សាស្បៀងនិងគ្រាប់ពូជ ការផលិតគ្រាប់ពូជ ប្រតិបត្តិការសង្គ្រោះបន្ទាន់ និងប្រតិបត្តិការផ្សេងៗដែលទាក់ទងនឹង **ប.ស.ប.គ.**
- រៀបចំប្លង់សរុបថវិកាប្រចាំឆ្នាំរបស់ **ប.ស.ប.គ.** ដែលស្នើឡើងដោយក្រសួងពាណិជ្ជកម្មសម្រាប់ស្បៀង និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សម្រាប់គ្រាប់ពូជ ដើម្បីស្នើសុំការអនុម័ត ដោយអនុលោមតាមបទប្បញ្ញត្តិ និងនីតិវិធីជាធរមាន
- គ្រប់គ្រងថវិកាទាំងអស់របស់ **ប.ស.ប.គ.**
- រៀបចំរបាយការណ៍ប្រចាំត្រីមាសនិងតាមការចាំបាច់ជូននាយករដ្ឋមន្ត្រីនិងជូនដំណឹងដល់ស្ថាប័នពាក់ព័ន្ធទាំងអស់ អំពីសភាពការណ៍ទូទៅរបស់ **ប.ស.ប.គ.**។

**មាត្រា២៣ ថ្មី.-**

គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ត្រូវប្រគល់តួនាទីជាអង្គភាពអនុវត្តក្នុង **ប.ស.ប.គ.** ដល់អគ្គលេខាធិការដ្ឋានរបស់ខ្លួន ដែលមានអគ្គលេខាធិការរងម្នាក់ទទួលបន្ទុក ដើម្បីបំពេញភារកិច្ចបន្ថែម ដូចខាងក្រោម÷

- គ្រប់គ្រងទិន្នន័យស្តីពីការប៉ាន់ប្រមាណនូវហានិភ័យនៃគ្រោះមហន្តរាយ ឬគ្រោះអាសន្ននានា
- រៀបចំនិងធ្វើការប៉ាន់ប្រមាណអំពីតម្រូវការស្បៀងនិងជួយធ្វើការប៉ាន់ប្រមាណគ្រាប់ពូជបន្ទាន់ នៅពេលមានគ្រោះមហន្តរាយ ឬគ្រោះអាសន្ននានា
- សម្របសម្រួលជាមួយស្ថាប័ននិងដៃគូអភិវឌ្ឍនានា ដើម្បីចែករំលែកព័ត៌មានស្តីពីតម្រូវការស្បៀងនិងគ្រាប់ពូជបន្ថែម
- រៀបចំរបាយការណ៍អំពីតម្រូវការស្បៀងបន្ទាន់ ជូននាយករដ្ឋមន្ត្រីដើម្បីជ្រាប ឬចាត់វិធានការចាំបាច់សម្រាប់ស្ថាប័នពាក់ព័ន្ធអនុវត្ត
- សម្របសម្រួលក្នុងការឆ្លើយតប នៅពេលមានគ្រោះមហន្តរាយ ឬគ្រោះអាសន្ននានាកើតឡើង
- សម្របសម្រួលក្នុងការកំណត់រកប្រជាពលរដ្ឋគោលដៅ ដែលទទួលរងផលប៉ះពាល់ដោយសារគ្រោះមហន្តរាយ ឬគ្រោះអាសន្ននានា
- សម្របសម្រួលការដឹកជញ្ជូននិងការដឹកនាំកិច្ចប្រតិបត្តិការចែកចាយស្បៀង និងគ្រាប់ពូជជូនដល់ប្រជាពលរដ្ឋរងគ្រោះ។

**មាត្រា២៤ ថ្មី.-**

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវប្រគល់តួនាទីជាអង្គភាពអនុវត្តក្នុង **ប.ស.ប.គ.** ដល់អគ្គនាយកដ្ឋានកសិកម្ម ដើម្បីបំពេញភារកិច្ចបន្ថែម ដូចខាងក្រោម÷

- ទទួលបន្ទុកប៉ាន់ប្រមាណអំពីការខូចខាតគ្រប់មុខដំណាំ និងតម្រូវការគ្រាប់ពូជបន្ទាន់ ដោយមានកិច្ចសហការជាមួយនឹងស្ថាប័ននិងអាជ្ញាធរពាក់ព័ន្ធ

- ជ្រើសរើសនិងចុះកិច្ចសន្យាសហការជាដៃគូ ជាមួយក្រុមហ៊ុននិងសហគមន៍កសិករដែលផលិតគ្រាប់ពូជ នៅក្នុង **ប.ស.ប.ក.** ដោយធានាបាននូវបរិមាណ និងគុណភាព
- សម្របសម្រួលក្នុងការចាត់ចែងផលិត និងការថែរក្សាជារួមនូវគ្រាប់ពូជបម្រុងរូបវន្តរបស់ **ប.ស.ប.ក.** ដែលមានគុណភាព ដោយសហការជាមួយក្រុមហ៊ុន និងសហគមន៍កសិករផលិតគ្រាប់ពូជ
- ធានាដឹកជញ្ជូនគ្រាប់ពូជបម្រុងទាន់ពេលវេលាទៅកាន់គោលដៅចែកចាយនៅក្នុង **ប.ស.ប.ក.**
- គ្រប់គ្រង តាមដាននិងត្រួតពិនិត្យបញ្ជីសារពើភណ្ឌនៃសន្និធិគ្រាប់ពូជបម្រុងរូបវន្តរបស់ **ប.ស.ប.ក.**
- គ្រប់គ្រងនិងត្រួតពិនិត្យសន្និធិគ្រាប់ពូជបម្រុងរូបវន្ត ដើម្បីធានាបរិមាណនិងគុណភាព
- រៀបចំសំណើផែនការថវិកាប្រចាំឆ្នាំ សម្រាប់កិច្ចលទ្ធកម្ម ការផលិត ការថែរក្សា ការគ្រប់គ្រង ការដឹកជញ្ជូន និងប្រតិបត្តិការផ្សេងៗពាក់ព័ន្ធនឹងគ្រាប់ពូជបម្រុងរូបវន្តរបស់ **ប.ស.ប.ក.**
- រៀបចំរបាយការណ៍ប្រចាំខែនិងតាមការចាំបាច់ ស្តីពីស្ថានភាពសន្និធិគ្រាប់ពូជបម្រុងរបស់ **ប.ស.ប.ក.**។

**មាត្រាពីរ.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រាបី.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី សូមចុះហត្ថលេខា

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**ប្រធានគណៈកម្មាធិការ ប.ស.ប.ក.**

**បណ្ឌិត អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល៖**

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រាបី
-រាជកិច្ច
-ឯកសារ កាលប្បវត្តិ